ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

# សាលដីកាប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ២៨៥

ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២

សាលដីកា

លេខ: ២៤៤

ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៣

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៣ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចខាងក្រោម:

១-ឯកឧត្តម [redacted] ជាប្រធាន

២-លោកស្រី [redacted] ជាចៅក្រម

៣-លោក [redacted] ជាចៅក្រម

៤-លោក [redacted] ជាចៅក្រម

៥-លោក [redacted] ជាចៅក្រម

ក្រឡាបញ្ជី

លោក [redacted]

តំណាងមហាអយ្យការ

លោក [redacted] ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ១០៤ក្រ.II ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ២៨៥ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ របស់តុលាការកំពូល។

ពីបទ: មនុស្សឃាតគិតទុកជាមុន ប្រព្រឹត្តនៅភូមិត្រពាំងឈ្នួ សង្កាត់សំរោងក្រោម ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា០៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

-ជនជាប់ចោទ ៖

១-ឈ្មោះ [redacted] ផា ហៅ ផា "ម្ចាស់បណ្តឹងសាទុក្ខ" ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ កើតនៅភូមិចំការស្បៀង សង្កាត់សំរោងក្រោម ស្រុកដង្កោ ខេត្តកណ្តាល [redacted] ភូមិចំការស្បៀង សង្កាត់សំរោងក្រោម ខណ្ឌដង្កោ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលើវ ទោសពីមុនគ្មាន។ ឃាត់ខ្លួន ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១០ ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៣៨៥ ត.ព្រ ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១០។



Scanned with CamScanner

២-ឈ្មោះ [redacted] ផល័គ ហៅ អៀន "ម្ចាស់បណ្តឹងសាទុក្ខ" ភេទប្រុស អាយុ២០ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីកន្លែងកំណើតនៅភូមិត្រពាំងឆ្នង់ សង្កាត់សំរោងក្រោម ស្រុកដង្កោ ក្រុងភ្នំពេញ [redacted] ខណ្ឌដង្កោ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនគ្មាន។

៣-ឈ្មោះ [redacted] តុ ហៅ តុ "ម្ចាស់បណ្តឹងសាទុក្ខ" ភេទប្រុស អាយុ២០ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីកន្លែងកំណើតនៅភូមិត្រពាំងឆ្នង់ សង្កាត់សំរោងក្រោម ស្រុកដង្កោ ក្រុងភ្នំពេញ [redacted] បច្ចុប្បន្នភូមិត្រពាំងឆ្នង់ សង្កាត់សំរោងក្រោម ខណ្ឌដង្កោ រាជធានីភ្នំពេញ សាសនាព្រះពុទ្ធ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនគ្មាន។

៤-ឈ្មោះ [redacted] វិចិត្រ "ម្ចាស់បណ្តឹងសាទុក្ខ" ភេទប្រុស អាយុ២០ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិត្រពាំងឆ្នង់ សង្កាត់សំរោងក្រោម ស្រុកដង្កោ ក្រុងភ្នំពេញ [redacted] ត្រពាំងឆ្នង់ សង្កាត់សំរោងក្រោម ខណ្ឌដង្កោ រាជធានីភ្នំពេញ សាសនាព្រះពុទ្ធ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted]) នៅលីវ ទោសពីមុនគ្មាន។

៥-ឈ្មោះ [redacted] ភ័ណ្ឌ "ម្ចាស់បណ្តឹងសាទុក្ខ" ភេទប្រុស អាយុ២៤ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីកន្លែងកំណើតនៅភូមិត្រពាំងឆ្នង់ សង្កាត់សំរោងក្រោម ស្រុកដង្កោ ក្រុងភ្នំពេញ [redacted] បច្ចុប្បន្ន[redacted] សង្កាត់សំរោងក្រោម ខណ្ឌដង្កោ រាជធានីភ្នំពេញ សាសនាព្រះពុទ្ធ ឪពុកឈ្មោះ [redacted](រ) ម្តាយឈ្មោះ[redacted](រ) នៅលីវ ទោសពីមុនគ្មាន។

៦-ឈ្មោះ [redacted] វង្ខា ហៅ វង្ខ "ម្ចាស់បណ្តឹងសាទុក្ខ" ភេទប្រុស អាយុ២២ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីកន្លែងកំណើតនៅភូមិត្រពាំងឆ្នង់ សង្កាត់សំរោងក្រោម ស្រុកដង្កោ ក្រុងភ្នំពេញ [redacted]ម ខណ្ឌដង្កោ រាជធានីភ្នំពេញ សាសនាព្រះពុទ្ធ ឪពុកឈ្មោះ [redacted] [redacted](រ) ម្តាយឈ្មោះ [redacted](រ) នៅលីវ ទោសពីមុនគ្មាន។

៧-ឈ្មោះ [redacted] សំណាង ហៅ រាជ "ម្ចាស់បណ្តឹងសាទុក្ខ" ភេទប្រុស អាយុ១៥ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីកន្លែងកំណើតនៅភូមិចំការស្បែង សង្កាត់សំរោងក្រោម ស្រុកដង្កោ ក្រុងភ្នំពេញ [redacted]ខណ្ឌដង្កោ រាជធានីភ្នំពេញ សាសនាព្រះពុទ្ធ ឪពុកឈ្មោះ [redacted](រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនគ្មាន។

-មានលោក [redacted]ធានិត និងលោក [redacted] កិរិយា មេធាវីការពារជនជាប់ចោទ

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] "ចុងបណ្តឹងសាទុក្ខ" ភេទស្រី អាយុ៣៥ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីលំនៅសព្វថ្ងៃភូមិត្រពាំងឆ្នង់ សង្កាត់សំរោងក្រោម ខណ្ឌដង្កោ រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted]ទឹក (ស) ម្តាយឈ្មោះ[redacted](រ) ប្តីឈ្មោះ [redacted] (ស)។



Scanned with CamScanner

-តាមពាក្យបណ្តឹងរបស់ជនរងគ្រោះឈ្មោះ [redacted] សុភា ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៨ ដែលបានប្តឹងពីឈ្មោះ [redacted] តឿ និងឈ្មោះ [redacted] វិចិត្រ រួមទាំងបក្សពួក០៥នាក់ បានធ្វើសកម្មភាពប្លន់វាយប្តីឈ្មោះ [redacted] សំភា បណ្តាលអោយស្លាប់ និងយកសំភារៈមួយចំនួន។ ក្រោយពីសមត្ថកិច្ចធ្វើការស្រាវជ្រាវរួចមកទើបដឹងថា ជនល្មើសមានចំនួន០៧នាក់ គឺឈ្មោះ [redacted] សំណាង, [redacted] ផល័ត, [redacted] វិចិត្រ, [redacted] ក័ណ្ហ, [redacted] ផា, [redacted] រង្គា និង [redacted] តុ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញថា:

+ប្តឹងសុំឱ្យចៅក្រមស៊ើបសួរសម្រេចៈ

បញ្ជូនជនត្រូវចោទឈ្មោះ [redacted] សំណាង ភេទប្រុស អាយុ១៥ឆ្នាំ, [redacted] ផល័ត ភេទប្រុស អាយុ២០ឆ្នាំ, [redacted] វិចិត្រ ភេទប្រុស អាយុ២០ឆ្នាំ, [redacted] ក័ណ្ហ ភេទប្រុស អាយុ២៤ឆ្នាំ [redacted] ផា ភេទប្រុស អាយុ២២ឆ្នាំ, [redacted] រង្គា ភេទប្រុស អាយុ២២ឆ្នាំ, [redacted] តុ ភេទប្រុស អាយុ២០ឆ្នាំ ទៅជំនុំជំរះ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ៤៨ ក្រ៦ "ជ" ចុះថ្ងៃទី ១២ ខែឧសភា ឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលបានសំរេចៈ

១-ផ្តន្ទាទោសឈ្មោះ ៖

ក. [redacted] សំណាង ហៅ រាជ ភេទប្រុស អាយុ១៥ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០៧ឆ្នាំ (ប្រាំពីរឆ្នាំ)

ខ. [redacted] ផល័ត ភេទប្រុស អាយុ២០ឆ្នាំ

គ. [redacted] វិចិត្រ ភេទប្រុស អាយុ២០ឆ្នាំ

ឃ. [redacted] ក័ណ្ហ ភេទប្រុស អាយុ២៤ឆ្នាំ

ង. [redacted] ផា ភេទប្រុស អាយុ២២ឆ្នាំ

ច. [redacted] រង្គា ភេទប្រុស អាយុ២២ឆ្នាំ

ឆ. [redacted] តុ ភេទប្រុស អាយុ២០ឆ្នាំ

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល១៥ឆ្នាំ (ដប់ប្រាំឆ្នាំ) ពីបទ មនុស្សឃាតគិតទុកជាមុន ប្រព្រឹត្តនៅភូមិត្រពាំងឈូក សង្កាត់សំរោងក្រោម ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងអោយផ្តន្ទាទោសតាមមាត្រា៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោស នៃបទឧក្រិដ្ឋ។

២-បង្គាប់អោយចាប់ខ្លួន និងឃុំខ្លួនឈ្មោះ [redacted] សំណាង ហៅ រាជ, [redacted] ផល័ត, [redacted] វិចិត្រ, [redacted] ក័ណ្ហ, [redacted] រង្គា, [redacted] តុ ទៅពន្ធនាគារ តាមមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។



Scanned with CamScanner

៣-បង្គាប់អោយឈ្មោះ [redacted] ផា, [redacted] ផល័ត, [redacted] វិចិត្រ, [redacted] ភ័ណ្ឌ, [redacted] វង្ហា [redacted] តុ និងអាណាព្យាបាលរបស់ឈ្មោះ [redacted] សំណាង រួមគ្នាសងជម្ងឺចិត្ត និងការខូចខាតទៅអោយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុភា ចំនួន៣០.០០០.០០០៛ (សាមសិបលានរៀល) ការទាមទារលើសពីនេះ បដិសេធចោល។

៤-វត្ថុតាងចាប់យក មានអាវដៃវែងចំនួន០១ ពណ៌ពងមាន់ឆ្អិត និងដែកជន្លាសចំនួន ០១ ត្រូវរឹបអូសបំផ្លាញចោល។

៥-សាលក្រមនេះ ជំនុំជំរះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១១ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ផា ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុភា កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] សំណាង ហៅ រាជ, [redacted] ផល័ត, [redacted] វិចិត្រ, [redacted] ភ័ណ្ឌ, [redacted] វង្ហា, [redacted] តុ បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ ក្នុងកំណត់ច្បាប់។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ៣៦០ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] ផា និងបណ្តឹងឧទ្ធរណ៍លេខ៣៧៤ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] ហៃ មេធាវីការពារឱ្យឈ្មោះ [redacted] ផល័ត ហៅ កឿន និងបណ្តឹងឧទ្ធរណ៍លេខ៣៩៦ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] រតនា មេធាវីការពារអោយឈ្មោះ [redacted] តុ, ឈ្មោះ [redacted] វិចិត្រ, ឈ្មោះ [redacted] សំណាង, ឈ្មោះ [redacted] ភ័ណ្ឌ, ឈ្មោះ [redacted] ផា, ឈ្មោះ [redacted] វង្ហា ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ៤៨ក្រVI"ជ" ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ គ្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថា៖

+យល់តាមអង្គហេតុ រឿងនេះអាចជារឿងគ្រោះថ្នាក់ចរាចរណ៍បើកម៉ូតូពេលយប់ដួលសន្លប់ (លើគំនរថ្ម) ម្នាក់ឯង យោងតាមចំលើយរបស់សាក្សី [redacted] តុលា ហើយនឹងសាក្សី [redacted] សំអាត ជានគរបាល ដែលបានទៅដល់កន្លែងកើតហេតុដំបូង នាវេលាម៉ោង១ និង៣០ នាទីយប់ ហើយការសង្ស័យលើជនជាប់ចោទទាំងអស់នេះ ថាបានប្រព្រឹត្តអំពើឃាតកម្មសំលាប់នោះ ក៏ធ្វើឡើងតាមការចង្អុលបង្ហាញរបស់ឈ្មោះ [redacted] សំអាត (នគរបាល) តាមរយៈបង្ហាញរូបថតប៉ុណ្ណោះ។

+ពុំឃើញមានភស្តុតាងដាក់បន្ទុកលើជនជាប់ចោទទាំង ៧នាក់ មានឈ្មោះ នាន់ ផា [redacted] ផល័ត, [redacted] តុ, [redacted] វិចិត្រ, [redacted] ភ័ណ្ឌ, [redacted] វង្ហា និង [redacted] សំណាង ពីបទ មនុស្សឃាតគិតទុកជាមុន ប្រព្រឹត្តកាលពីថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៨ នៅភូមិត្រពាំងធ្នង់ សង្កាត់សំរោងក្រោម នោះទេ។

ករណីនេះ គួរជូនក្រុមប្រឹក្សាជំនុំជំរះនៃសាលាឧទ្ធរណ៍ពិចារណា សំរេចតាមច្បាប់។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៤៦ ក្រII ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេច៖



Scanned with CamScanner

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ៣៦០ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១១ របស់ជនជាប់ចោទឈ្មោះ[redacted] ផា បណ្តឹងឧទ្ធរណ៍លេខ៣៧៤ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១១ របស់លោកមេធាវី [redacted] ហៃ បណ្តឹងឧទ្ធរណ៍លេខ៣៩៦ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១១ របស់លោកមេធាវី [redacted]រតនា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ៤៨ ក្រ៦ "ជ" ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការពេញទាំងមូល។

៣-សាលដីកានេះ ជំនុំជម្រះនៅថ្ងៃទី០២ ខែមេសា ឆ្នាំ២០១២ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២។ បើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់។

-បានឃើញបណ្តឹងបណ្តឹងទាស់លេខ៤៩ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] សោភ័ណ [redacted] វិចិត្រ, [redacted]វឌ្ឍា, [redacted] សំណាង, [redacted] តុ, [redacted] ផល័គ ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ៤៦ក្រII ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ១០៤ ក្រII ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចៈ

១-ទទួលបណ្តឹងទាស់របស់ជនជាប់ចោទទាំងអស់ដូចខាងលើ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២-តម្កល់សាលដីកាកំបាំងមុខលេខ៤៦ ក្រII ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល។

៣-សាលដីកានេះ ជំនុំជម្រះនៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២ និងប្រកាសជាសាធារណៈនៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១២។ បើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់។

-បានឃើញបណ្តឹងសាទុក្ខលេខ១៤១ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២ របស់លោក [redacted] ជានិត មេធាវីការពារជនជាប់ចោទឈ្មោះ[redacted] ផា ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ៤៦ក្រII ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២ និងបណ្តឹងសាទុក្ខលេខ៣៤៦ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ របស់ឈ្មោះ [redacted] ភ័ណ្ឌ, ឈ្មោះ[redacted] វិចិត្រ, ឈ្មោះ [redacted] វឌ្ឍា, ឈ្មោះ[redacted] តុ, ឈ្មោះ [redacted] ផល័គ និងឈ្មោះ [redacted] សំណាង ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ១០៤ក្រII ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល។

-បានឃើញសារណាការពាររបស់លោក [redacted] ជានិត មេធាវីការពារឱ្យឈ្មោះ [redacted] ភ័ណ្ឌ, ឈ្មោះ [redacted] វិចិត្រ, [redacted] វឌ្ឍា, ឈ្មោះ [redacted] តុ, ឈ្មោះ [redacted] ផល័គ, ឈ្មោះ [redacted] សំណាង និងឈ្មោះ [redacted] ផា ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៣។



Scanned with CamScanner

-បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា:

១-ទទួលបណ្តឹងសាទុក្ខលេខ៣៤៦ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ជនជាប់ចោទឈ្មោះ [redacted] ភ័ណ្ឌា, [redacted] វិចិត្រ, [redacted] រដ្ឋា, [redacted] តុ, [redacted] ផល័ត និងឈ្មោះ [redacted] សំណាង និងបណ្តឹងសាទុក្ខលេខ១៤១ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២ របស់លោក [redacted] ផានិត មេធាវីការពារជនជាប់ចោទឈ្មោះ [redacted] ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់។

២-បដិសេធសាលដីកាព្រហ្មទណ្ឌលេខ៤៦ក្រII ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២ និងសាលដីកាព្រហ្មទណ្ឌលេខ១០៤ក្រII ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ចោលជាអសារបង់។

សូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិនិត្យ និងសម្រេចតាមច្បាប់។

-បានស្តាប់សាវតាជាតិ និងចម្លើយអះអាងរបស់ជនជាប់ចោទឈ្មោះ [redacted] ផា នាពេលសវនាការថា: មូលហេតុអ្វីបានជាលោកប្តឹងសាទុក្ខ? ខ្លួនមិនបានប្រព្រឹត្តទេ តែត្រូវបានផ្តន្ទាទោសរយៈពេល១៥ឆ្នាំក្នុងរឿងនេះខ្លួនមិនបានដឹងទេ ឯជនជាប់ចោទផ្សេងៗទៀតជាអ្នករស់នៅក្នុងភូមិជាមួយគ្នា។ ពេលកើតហេតុនោះខ្លួនមិនបានដឹងទេ ខ្លួនបានដេកលក់ហើយ។ ខ្លួនទៅផឹកស្រានៅផ្ទះតាកៅ យាយនួន ដែលលក់ចាប់ហួយ មានពួកខ្លួន១០នាក់ សំណាង, [redacted] ភ័ណ្ឌា, ផល័ត, ផា, ផឹកចប់នៅម៉ោង៨-៩ ទៅផឹកលើកទី២ មានគ្នា៥ទៅ៦នាក់ ចប់នៅម៉ោងប្រហែល១០។ តើមូលហេតុអ្វីបានជានាំគ្នារត់? ខ្លួនទៅហូបកាហ្វេលឺគេថា មានមនុស្សស្លាប់ ខ្លួនក៏ទៅកន្លែងធ្វើឡាននៅផ្សារដេប៉ូក្រោយមកមិត្តភ័ក្តខ្លួនថា ទៅធ្វើឡាននៅរតនគីរីរកលុយបានច្រើនជាង ទើបខ្លួនទៅ។ ក្រោយថ្ងៃកើតហេតុ៤-៥ថ្ងៃ ខ្លួនបានជិះម៉ូតូទៅផ្ទះរបស់ខ្លួនដែរ តែមិនមានការចាប់ខ្លួនទេ តែបានលឺគេថាប៉ូលីសដេញចាប់អ្នកផឹកស្រាជាមួយខ្លួនកាលពីយប់មិញ។

សំណូមពរ: សុំឱ្យតុលាការស្រាវជ្រាវ និងលើកលែងចោទប្រកាន់ឱ្យខ្លួនផង។

-បានស្តាប់សេចក្តីសន្និដ្ឋានលោក [redacted] ផានិត មេធាវីការពារឱ្យជនជាប់ចោទ នាពេលសវនាការថា: ម៉ូតូរបស់ជនរងគ្រោះត្រូវបានប្រគល់ឱ្យជនរងគ្រោះវិញហើយ។ របាយការណ៍របស់ប៉ូលីស មិនបានបញ្ជាក់ថា មិនមានករណីប្លន់ និងមនុស្សឃាតទេ ជាគ្រោះថ្នាក់ចរាចរណ៍។ សាក្សីអ្នករកត្រីពេលយប់ឡើង គាត់មករកត្រីជាមួយក្មេងប្រុសឃើញម៉ូតូដួលនៅជិតជនរងគ្រោះ ពេលនោះខ្លួនក៏បានទៅហៅប៉ូលិស ពេលមកវិញឃើញមនុស្ស២នាក់ជិះម៉ូតូនោះ ហើយប៉ូលីសក៏បានបាញ់កាំភ្លើង ក៏ជន២នាក់នោះផ្តួលម៉ូតូរត់គេចខ្លួនបាត់ បន្សល់ទុកម៉ូតូ។ ឯដែកសន្ទាសឡានវិញ គឺរើសបាននៅកន្លែងផ្សេងទៀតទេ។ ប្រពន្ធជនរងគ្រោះបានសម្រេចចិត្តដកបណ្តឹងវិញ ហើយថាអ្នកទាំងនោះ



Scanned with CamScanner

មិនបានប្រព្រឹត្តបទល្មើសមកលើប្តីខ្លួនទេ។ រាប់ទាំងសាក្សី និងប៉ូលិសបញ្ជាក់ថា កូនក្តីខ្លួនទាំង៦នាក់ មិនបានប្រព្រឹត្តបទល្មើសទេ។

សំណូមពរៈ ស្នើសុំក្រុមព្រឹក្សាជំនុំជំរះ មេត្តាពិនិត្យលើគោលការណ៍វិមតិសង្ស័យ និងស្នើសុំ បដិសេធសាលដីកាសាលាឧទ្ធរណ៍ និងសម្រេចឲ្យកូនក្តីខ្លួនរួចផុតពីបទចោទ។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការអមតុលាការកំពូលថាៈ ពុំមានយោបល់អ្វីបន្ថែមទៀតទេ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទឈ្មោះ [redacted] ផា និងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីអោយជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## <u>តុលាការកំពូល</u>

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ៣៤៦ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ របស់ឈ្មោះ[redacted]ណ្ឌ [redacted]វិចិត្រ, [redacted]រង្គា, [redacted] តុ, [redacted] ផល័ត និងឈ្មោះ [redacted] សំណាង និងបណ្តឹងសាទុក្ខលេខ១៤១ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២ របស់លោក [redacted]ផានិត មេធាវី ការពារជនជាប់ចោទឈ្មោះ [redacted] ផា ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និងមាត្រា៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌតុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបាន។

-យល់ឃើញថា ការដែលសាលាដំបូងរាជធានីភ្នំពេញ និងសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ សំរេចផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] ភ័ណ្ឌ,[redacted] ផា, [redacted]ចិត្រ, [redacted] រង្គា,[redacted] តុ, [redacted] ផល័ត និងឈ្មោះ [redacted]សំណាង ដាក់ពន្ធនាគារក្នុងម្នាក់ៗ កំណត់រយៈពេល១៥ឆ្នាំ ពីបទមនុស្សឃាតគិតទុកជាមុន ប្រព្រឹត្តនៅភូមិត្រពាំងឈូង សង្កាត់សំរោងក្រោម ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៨ តាមមាត្រា០៣ នៃច្បាប់ស្តីពីស្តានទម្ងន់ទោសនៃបទឧក្រិដ្ឋនោះ <u>ពុំទាន់មានមូលដ្ឋានគ្រប់គ្រាន់ដើម្បីកំណត់អង្គហេតុ នៃបទល្មើស និងធាតុផ្សំនៃបទល្មើសលើជនជាប់ចោទម្នាក់ៗអោយបានច្បាស់លាស់ទេ។ ទាំងសាលាដំបូង ទាំងសាលាឧទ្ធរណ៍ ក្នុងការយល់ឃើញពុំឃើញមានបង្ហាញនូវអង្គហេតុស្ថាពរ ដែលកំណត់ថា ជនត្រូវចោទម្នាក់ៗ មានសកម្មភាពយ៉ាងដូចម្តេចនៅក្នុងបទល្មើសនេះឡើយ។ ដូច្នេះសាលដីការបស់សាលាឧទ្ធរណ៍នេះ មានកំហុសរំលោភទៅលើមាត្រា៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។</u>



Scanned with CamScanner

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ៤៦ក្រII ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២ និង សាលដីកាសភាព្រហ្មទណ្ឌលេខ១០៤ក្រII ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះទាស់នឹងគតិច្បាប់។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១-ទទួលបណ្តឹងសាទុក្ខលេខ១៤១ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២ របស់លោក ថាន ផានិត មេធាវី ការពារជនជាប់ចោទឈ្មោះ នាន់ ផា និងបណ្តឹងសាទុក្ខលេខ៣៤៦ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ របស់ឈ្មោះ ឈ្មោះ [redacted]ភ័ណ្ឌ, [redacted]វិចិត្រ, [redacted]ផ្កា, [redacted]តុ, [redacted]ផល័ត និងឈ្មោះ [redacted]សំណាង។

២-បដិសេធសាលដីកាសភាព្រហ្មទណ្ឌលេខ៤៦ក្រII ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២ និង សាលដីកាសភាព្រហ្មទណ្ឌលេខ១០៤ក្រII ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍។

៣-បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ២៨៥ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-សាលដីកានេះ ជំនុំជំរះជាសាធារណៈនៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៣ និងប្រកាសជាសាធារណៈ ថ្ងៃទី០៩ ខែតុលា ២០១៣។

| ប្រធាន | ចៅក្រម | ចៅក្រម | ចៅក្រម | ចៅក្រម | ក្រឡាបញ្ជី |
|---|---|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] | [redacted] | [redacted] |

បានចម្លងចេញពីសាលដីកាដើមត្រឹមត្រូវហើយ។
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ១០ ឆ្នាំ២០១៣
ក្រឡាបញ្ជី
[redacted]

បានឃើញ
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ១០ ឆ្នាំ២០១៣
ប្រធានតុលាការកំពូល
[redacted]



Scanned with CamScanner